PARTNERSHIP FOR LOCALGOVERNANCE
REFERENCE COPY
EDU/MAN – 181

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងផែនការ
លេខ១៥០ផក.សណ

# សេចក្តីណែនាំ
# ស្តីពី
# ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំសង្កាត់

យោងតាមប្រកាសណែនាំអន្តរក្រសួង មហាផ្ទៃ និងក្រសួងផែនការ លេខ៥៥ប្រក ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០០២ ស្តីពី ការប្រើប្រាស់សេចក្តីណែនាំពីដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំសង្កាត់ និងទំរង់គំរូសៀវភៅផែន ការអភិវឌ្ឍន៍ ឃុំសង្កាត់៥ឆ្នាំ និង កម្មវិធីវិនិយោគឃុំសង្កាត់៣ឆ្នាំរំកិល ( ២០០៣-២០០៥ ) ក្នុងប្រការ៣ ឧបសម្ព័ន្ធទី ២ កថាខ័ណ្ឌទី ២ ជំពូកទី៣ ក្រសួងផែនការសូមធ្វើការណែនាំពីការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំសង្កាត់ ដូចតទៅ ÷

កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំសង្កាត់ ( សរសេរកាត់ ក.វិ.ឃស) ត្រូវមានទំរង់ ដូចខាង ក្រោមៈ

**អារម្ភកថាៈ** ត្រូវមានចុះហត្ថលេខាបញ្ជាក់ពីការអនុម័តរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ។

**សេចក្តីផ្តើមៈ** ត្រូវសរសេររៀបរាប់ដោយសង្ខេបពីចំណុចសំខាន់ៗរបស់កម្មវិធីវិនិយោគ ។

**ផែនទីៈ** ដោយបង្ហាញពីទីតាំងសំខាន់ៗនៃការអភិវឌ្ឍន៍របស់ឃុំសង្កាត់និងសមិទ្ធផលនានា ។

**ជំពូកទី១:** ការវិភាគពីស្ថានភាពអភិវឌ្ឍន៍របស់ឃុំសង្កាត់

ក) ផ្នែកសេដ្ឋកិច្ច

ខ) ផ្នែកសង្គមកិច្ច

គ) ផ្នែកធនធានធម្មជាតិនិងបរិស្ថាន

ឃ) ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ

ង) ផ្នែកយេនឌ័រ

**ជំពូកទី២:** ទិសដៅបន្ទាន់ និងយុទ្ធសាស្ត្រសំរាប់ការវិនិយោគ

ក) ទិសដៅបន្ទាន់

ខ) យុទ្ធសាស្ត្រសំរាប់ការវិនិយោគ

២៧៦

**ជំពូកទី៣:** គំរោងវិនិយោគបីឆ្នាំរំកិល

ក) តារាងគំរោងវិនិយោគឃុំសង្កាត់បីឆ្នាំរំកិល

ខ) តារាងថវិកាវិនិយោគតាមប្រភពផ្តល់

**ឧបសម្ព័ន្ធ:** ប្រើសំរាប់ភ្ជាប់តារាងចាំបាច់នានា ដែលមិនបានកំណត់នៅក្នុងផ្នែកខាងលើ ។

គណៈកម្មាធិការកសាងផែនការនិងថវិការបស់ឃុំសង្កាត់ (ហៅកាត់ថា គ.ផ.ថ) ត្រូវរៀបចំកាលវិភាគការងារ ដើម្បីធ្វើការពិភាក្សា និងព្រមព្រៀងលើខ្លឹមសារចំនុចនិមួយៗនៃមាតិកា អោយបានច្បាស់លាស់ និងកំណត់បែងចែកគំរោងវិនិយោគ ទៅតាមប្រភពនៃថវិកា ដូចជាគំរោងត្រូវប្រើប្រាស់មូលនិធិឃុំ សង្កាត់ គំរោងដែលបានទទួលការគាំទ្រពីសប្បុរសជន អង្គការមិនមែនរដ្ឋាភិបាល ឬមន្ទីរជំនាញនានា នៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ ។

*ក្នុងការវិភាគពីស្ថានភាពអភិវឌ្ឍន៍របស់ឃុំ សង្កាត់ គ.ផ.ថ ត្រូវអនុវត្តទៅតាមជំហានការងារសំខាន់ៗ ដូចតទៅ:*

**ជំហានទី១:** <u>ការកំណត់បញ្ហាឬតំរូវការនៅថ្នាក់ឃុំ សង្កាត់</u>

នៅក្នុងការប្រជុំនេះ គ.ផ.ថ ត្រូវពិភាក្សាវាយតំលៃអំពីកំរិតអភិវឌ្ឍន៍របស់ឃុំ សង្កាត់ខ្លួន នាពេលបច្ចុប្បន្ន ដែលទាក់ទងទៅនឹង ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិនិងបរិស្ថាន សេវាកម្មរដ្ឋបាលនិងសន្តិសុខ និង យេនឌ័រ ដោយប្រើប្រាស់ឯកសារពតិមានស្ថានភាពឃុំសង្កាត់ ដែលទទួលបានពីអភិបាលខេត្ត ក្រុង និងផែនទីឃុំសង្កាត់ និងឧបករណ៍វិភាគផ្សេងៗទៀត ដូចជាការវិភាគយេនឌ័រ និងការវិភាគផ្នែកធនធានធម្មជាតិនិងបរិស្ថានជាដើម ។ល។ រាល់បញ្ហាគន្លឹះ ដែលបានពិភាក្សាគ្នា ត្រូវកំណត់ទីតាំងច្បាស់លាស់នៅលើផែនទីឃុំ សង្កាត់ ។ បន្ទាប់មកទើបព្រាងបញ្ហានិងសេចក្តីត្រូវការ សំរាប់ថ្នាក់ឃុំសង្កាត់ នៅលើផែនទីដែរ សំរាប់ធ្វើការពិចារណាអំពីសកម្មភាព ដែលគ្រោងអនុវត្តដោះស្រាយ តាមបញ្ហានិងសេចក្តីត្រូវការទាំងនោះ ។ ឃុំសង្កាត់ ត្រូវស្រង់យកតំរូវការវិនិយោគ ដែលអង្គប្រជុំបានឯកភាពដាក់ទៅក្នុងតារាងមួយ សំរាប់ពិភាក្សាបន្តនៅជំហានក្រោយៗទៀត ។

ចំពោះឃុំសង្កាត់ណាដែលមានជនជាតិដើមភាគតិចរស់នៅ ត្រូវមានតំនាងជនជាតិដើមភាគតិចចូលរួមពិភាក្សា និងឯកភាព ជាតំណាងអោយផលប្រយោជន៍ក្រុមជនជាតិដើមភាគតិចរបស់ខ្លួន ។

បន្ទាប់ពីបានកំណត់បញ្ហាឬតំរូវការនានា នៅក្នុងការប្រជុំនៅឃុំសង្កាត់ គ.ផ.ថ ត្រូវធ្វើការចាត់តាំង និងរៀបចំកាលវិភាគការងារ អោយតំនាងភូមិដែលជាសមាជិកគ.ផ.ថ ពិនិត្យស្ថានភាពជាក់ស្តែង និងស្រង់យកយោបល់របស់អ្នកភូមិ ។ តំណាងភូមិជាសមាជិកគ.ផ.ថ ត្រូវធ្វើការពិភាក្សាយោបល់ជាមួយប្រជាជនក្នុងភូមិ ដើម្បីផ្តល់ឱកាស

អោយប្រជាជនបញ្ចេញទស្សនៈ អំពីការអភិវឌ្ឍន៍មូលដ្ឋានខ្លួន និងពិនិត្យស្វែងរកឬសគល់នៃបញ្ហា ព្រមទាំងលទ្ធភាពដោះស្រាយ ក៏ដូចជាលទ្ធភាពចូលរួមចំណែករបស់ប្រជាជននៅក្នុងភូមិ បើគំរោងត្រូវបានអនុវត្តក្នុងភូមិ ។

តំនាងភូមិត្រូវត្រៀមខ្លួនអោយបានល្អប្រសើរ និងយល់អោយបានច្បាស់ពីវិធីបំផុសយោបល់ ជាមួយប្រជាជននៅក្នុងភូមិ ។ ចំពោះភូមិដែលមានជនជាតិដើមភាគតិចរស់នៅ ត្រូវត្រៀមអ្នកបកប្រែជាភាសា ដើម្បីអោយក្រុមជនជាតិដើមភាគតិច ដែលចូលរួមអាចយល់បានច្បាស់លាស់ និងចូលរួមពិភាក្សា ។

**ជំហានទី២:** <u>ការប្រជុំពិភាក្សាជាមួយប្រជាជនក្នុងភូមិ</u>

តំនាងភូមិដែលត្រូវចាត់តាំងអោយរៀបចំការប្រជុំភូមិ ត្រូវៈ

- អញ្ជើញតំនាងគ្រួសារគ្រប់គ្រួសារអោយមកចូលរួមប្រជុំ តាមពេលវេលានិងទីតាំងកំណត់ ។ ចំពោះទីប្រជុំជន ដែលជួបប្រទះការលំបាកលើពេលវេលាចូលរួម ឃុំសង្កាត់ ត្រូវជ្រើសរើសវិធីសមស្របមួយចំនួន ដែលអាចអោយអ្នកភូមិបានចូលរួមផ្តល់យោបល់បានច្រើនបំផុត ។

- គូរពិភាក្សាជាមួយអ្នកភូមិ ដើម្បីកំណត់ទីតាំងធនធាននានាដែលមាន និងកំណត់ទីតាំងដែលមានបញ្ហាចោទ ឬទីតាំងដែលអាចប៉ះពាល់ដល់បរិស្ថាននៅលើផែនទី ។ ចំពោះភូមិ ដែលមានជនជាតិដើមភាគតិច រស់នៅ ត្រូវធ្វើការពិភាក្សានិងកំណត់ពីតំបន់ជាប្រពៃណីរបស់ជនជាតិដើមភាគតិចទាំងនោះ អោយបានច្បាស់លាស់ នៅលើផែនទីឃុំ សង្កាត់ ។ ពេលប្រជុំត្រូវមានការបកប្រែជាភាសាជនជាតិ ដើម្បីអោយក្រុមជនជាតិដើមភាគតិច ដែលចូលរួមអាចយល់បានច្បាស់លាស់ ។

- លើកយកបញ្ហាដែលបានពិភាក្សានៅថ្នាក់ឃុំ មកពិភាក្សាឡើងវិញនៅក្នុងអង្គប្រជុំភូមិ ដើម្បីស្វែងរកការពិត ដែលកើតមានឡើងនៅក្នុងភូមិ និងដំណោះស្រាយអ្វីដែលអាចធ្វើទៅបាន ទៅតាម ស្ថានភាពភូមិនិមួយ១ និងបំណងប្រាថ្នារបស់អ្នកភូមិទូទៅ ។

- ការពិភាក្សាត្រូវប្រមូលអោយបាននូវរាល់គំនិតយោបល់ សំណូមពរ បំណងប្រាថ្នា និង ដំណោះស្រាយ ដែលស្នើឡើងដោយប្រជាពលរដ្ឋទាំងពីរភេទនៅក្នុងភូមិ ។

- រាល់ការពិភាក្សា ត្រូវមានការកត់ត្រាតាមទំរង់ឯកភាពមួយសំរាប់យកទៅពិភាក្សាបន្តនៅថ្នាក់ឃុំ ។

**ជំហានទី៣:** <u>ការប្រជុំកំណត់បញ្ហាឬតំរូវការនៅឃុំសង្កាត់</u>

បន្ទាប់ពីការប្រជុំនៅថ្នាក់ភូមិ បានបញ្ចប់ គ.ផ.ថ ត្រូវរៀបចំការប្រជុំបូកសរុបលទ្ធផលម្តងទៀត នៅថ្នាក់ឃុំសង្កាត់ ដើម្បីស្រង់យកបញ្ហាឬតំរូវការ និងដំណោះស្រាយដែលបានលើកឡើងនៅថ្នាក់ភូមិ យកមកផ្ទៀងផ្ទាត់បញ្ចូលគ្នាជាមួយបញ្ហាឬតំរូវការ និងដំណោះស្រាយ ដែលបានរកឃើញ នៅពេលពិភាក្សាលើកមុនក្នុងជំហានទី១ ។ រាល់បញ្ហា ឬតំរូវការទាំងអស់ ក៏ដូចជាដំណោះស្រាយ ត្រូវកត់ត្រាសំរាប់ការពិភាក្សាជំហានក្រោយទៀត ។

*ក្នុងការកំណត់ទិសដៅបន្ទាន់ និងយុទ្ធសាស្ត្រសំរាប់ការវិនិយោគ គ.ជ.ថ ត្រូវអនុវត្តតាមជំហានដូចខាងក្រោម :*

**ជំហានទី៤:** <u>ការកំណត់ទិសដៅនិងយុទ្ធសាស្ត្រវិនិយោគ</u>

គ.ជ.ថ ត្រូវពិនិត្យមើលឡើងវិញនូវទិសដៅ និងយុទ្ធសាស្ត្រដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ របស់ខ្លួន ដោយយកបញ្ហាឬតំរូវការ ដែលពិភាក្សានិងឯកភាពនៅក្នុងជំហានទី១ ជំហានទី២ និងជំហានទី៣ មកពិនិត្យ ពិចារណារ ដើម្បីរៀបចំទិសដៅ និងយុទ្ធសាស្ត្រវិនិយោគថ្មី ដោយផ្អែកទៅលើសកម្មភាពដែលស្របទៅតាមពេលវេលានិងស្ថានភាពជាក់ ស្តែង និងមិនឃ្លាតឆ្ងាយពីក្របខ័ណ្ឌអភិវឌ្ឍន៏ក្នុងផែនការ៥ឆ្នាំ របស់ឃុំ សង្កាត់ ។

*ក្នុងការកំណត់គំរោងវិនិយោគបីឆ្នាំរំកិល ប្រកបដោយការពិចារណាត្រឹមត្រូវ និងមានការគាំទ្រ គ.ជ.ថ ត្រូវអនុវត្តការងារតាមជំហានដូចខាងក្រោម*

**ជំហានទី៥:** <u>ការកំណត់គំរោងដែលត្រូវវិនិយោគ</u>

រាល់សកម្មភាពនិងដំណោះស្រាយ ដែលអាចរៀបចំជាគំរោងវិនិយោគបាន ត្រូវសរសេរជាឈ្មោះគំរោង ដោយកំណត់ទីតាំង និងទំហំគំរោង និងប៉ាន់ស្មានតំលៃគំរោង ។ គ.ជ.ថ អាចយកបញ្ជីគំរោងដែលបានរៀបចំរួចនៅឆ្នាំមុនមកពិនិត្យ ហើយសរសេរឈ្មោះគំរោងនិងពត៌មានផ្សេងទៀតអោយបានត្រឹមត្រូវ ។

គំរោងទាំងឡាយដែលបានកំណត់ក្នុងជំហាននេះ នឹងត្រូវយកមកពិនិត្យឡើងវិញរៀងរាល់ឆ្នាំ ហេតុនេះ ឃុំសង្កាត់ ត្រូវកត់ត្រានិងរក្សាទុកឯកសារអោយបានល្អប្រសើរ ។

**ជំហានទី៦:** <u>ការព្យាករណ៏ទុនវិនិយោគ</u>

គ.ជ.ថ ត្រូវស្វែងរកពត៌មានពីគណនេយ្យករឃុំសង្កាត់ ដើម្បីអោយដឹងថាឃុំសង្កាត់ នៅឆ្នាំក្រោយអាចមានថវិកាសំរាប់វិនិយោគប៉ុន្មាន ។ ករណីគ្មានពត៌មានជាក់លាក់ គ.ជ.ថ ត្រូវរក្សាទុកការពិភាក្សាជំហាននេះ នៅក្រោយពេលធ្វើសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកខណ្ឌ ដោយចាត់ទុកជាបណ្តោះអាសន្នថា គំរោងទាំងអស់នេះជាគំរោងគ្មានថវិកាអនុវត្ត ដែលត្រូវស្វែងរកទុនពីប្រភពផ្សេងៗទៀតមកគាំទ្រ ។

**ជំហានទី៧:** <u>ការរៀបចំតារាងគំរោងវិនិយោគជាអាទិភាព</u>

រាល់គំរោងវិនិយោគឃុំសង្កាត់ ដែលបានកំណត់នៅជំហានទី៥ ហើយមិនមានថវិកាអនុវត្តដូចបានពិភាក្សានៅជំហានទី៦ ត្រូវធ្វើការជ្រើសរើសនិងឯកភាពក្នុងគ.ជ.ថ និងរៀបចំជាបញ្ជីគំរោងអាទិភាពមួយ ផ្ញើរទៅកាន់មន្ទីរផែនការខេត្តក្រុង ដើម្បីដាក់បញ្ចូលសំរាប់ការពិភាក្សាគៀងគររកការគាំទ្រ នៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកខណ្ឌ ។

ក្រុមប្រឹក្សាឃុំសង្កាត់ គួរមានទំនាក់ទំនងល្អជាមុន ជាមួយអ្នកគាំទ្រគំរោង ដូចជា គ្រប់អង្គការ សប្បុរសជន ឬមន្ទីរជំនាញនានា ជាដើម ដើម្បីស្វែងយល់ពីគោលបំណង ទំនោរនៃការគាំទ្រ និងជ្រើសរើសគំរោងដែលសមស្រប សំរាប់ដាក់បញ្ចូលទៅក្នុង បញ្ជីគំរោងអាទិភាព ផ្ញើទៅមន្ទីរផែនការ ។ ម្យ៉ាងទៀត ឃុំសង្កាត់ អាចផ្អែកលើ បទពិសោធន៍ដែលទទួលបានពី សិក្ខាសាលាសមាហរណកម្មផែនការនាឆ្នាំមុនៗ ធ្វើការប៉ាន់ស្មានពីប្រភេទគំរោងដែល ភាគច្រើនមានការគាំទ្រ នៅក្នុង សិក្ខាសាលាសមាហរណកម្មផែនការស្រុកខណ្ឌ ។

## **ជំហានទី៨:** <u>ការរៀបចំសមាហរណកម្មផែនការថ្នាក់ស្រុកខណ្ឌ</u>

ការរៀបចំនិងសំរបសំរួលសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកខណ្ឌ គឺជាភារៈកិច្ចរបស់មន្ទីរផែនការ ខេត្តក្រុង ប៉ុន្តែឃុំសង្កាត់ត្រូវឡើងបង្ហាញនិងឆ្លើយបំភ្លឺរាល់ចំងល់ផ្សេងៗ ដែលពាក់ព័ន្ធនិងគំរោងវិនិយោគ របស់ ឃុំសង្កាត់ខ្លួន ។

មុនពេលចូលរួមសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ គ.ផ.ថ ត្រូវចាត់តាំងអ្នកដែលត្រូវចូល រួមជាតំនាងឃុំសង្កាត់ និងដើម្បីបង្ហាញពីគំរោងអភិវឌ្ឍន៏នានា ។ ការងារនេះអាចរៀបចំទៅបានល្អប្រសើរ លុះត្រាតែ មានការសាកល្បងជាមុន ក្រោមការជួយណែនាំរបស់អ្នកសំរបសំរួលស្រុក ខណ្ឌ ។

ស្រុកខណ្ឌអាចអញ្ជើញអ្នកគាំទ្រគំរោងមកចូលរួមក្នុងសិក្ខាសាលាសមាហរណកម្មផែនការ ទៅតាមសំណើរ របស់ឃុំសង្កាត់ដែលបានទំនាក់ទំនងមុន ហើយឃុំ សង្កាត់ អាចអញ្ជើញបន្ថែមទៀតនូវអ្នកដែលគាំទ្រគំរោងរបស់ ខ្លួន ដែលបានស្នើសុំទៅស្រុក ខណ្ឌ ។

## **ជំហានទី៩:** <u>ការសំរេចចុងក្រោយលើគំរោងនានាក្នុងកម្មវិធីវិនិយោគឃុំសង្កាត់</u>

ក្រោយពីសិក្ខាសាលាសហមាហរណកម្មផែនការស្រុកខណ្ឌបានបញ្ចប់ គ.ផ.ថត្រូវពិនិត្យជ្រើសរើសគំរោង ដែលត្រូវប្រើធនធានថវិកាឃុំសង្កាត់ តាមលក្ខណៈវិនិច្ឆ័យដែលសមស្របបំផុត ។ ការសំរេចនេះ ត្រូវមានការឯកភាព ពីសមាជិក គ.ផ.ថភាគច្រើន និងជាដំណោះស្រាយគន្លឹះ សំរាប់កិច្ចអភិវឌ្ឍន៏ឃុំសង្កាត់ ដូចបានពិភាក្សាក្នុងជំហានទី១ ទី២ និងទី៣ ។ គ.ផ.ថ ត្រូវពិភាក្សា និងធ្វើការបែងចែកគំរោងជាចង្កោម សំរាប់ជំរុញការអនុវត្តន៏កិច្ចព្រមព្រៀង បណ្តោះអាសន្ន ដែលបានចុះហត្ថលេខានៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកខណ្ឌ ។ ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវចាត់តាំងសមាជិកឬជនបង្គោល ជួយសំរបសំរួលដល់ការអនុវត្តន៏គំរោងទាំងនោះ ។

គ.ផ.ថ ត្រូវរៀបចំផែនទីឃុំសង្កាត់របស់ខ្លួន ដោយដៅកំណត់ពីទីតាំងរបស់គំរោង ប្រភេទដីប្រើប្រាស់ តំបន់ត្រូវហាមឃាត់ ដីសំរាប់អភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធ តំបន់ជំនឿប្រពៃណីរបស់ជនជាតិដើមភាគតិច ។ល ។

៦៤០

**ជំហានទី១០:** ការចងក្រងសៀវភៅកម្មវិធីវិនិយោគឃុំសង្កាត់

ក្រោយពីមានការឯកភាព ក្រុមការងារនៃគ.ផ.ថ ត្រូវប្រមូលផ្តុំឯកសារដែលបានពិភាក្សាគ្រប់ជំហាន ដូចជា ការវិភាគស្ថានភាពឃុំសង្កាត់ ទិសដៅនិងយុទ្ធសាស្ត្រ និងបញ្ជីគំរោងវិនិយោគដែលមានការគាំទ្រ និងគំរោងវិនិយោគ ដែលគ្មានការគាំទ្រ មកចងក្រងជាសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់ ស្របទៅតាមទំរង់កំណត់ ខាងលើ ហើយដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យនិងសំរេចលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដើម្បី ផ្ញើទៅអ្នកពាក់ព័ន្ធ និងផ្ញើជូនអភិបាលខេត្តក្រុង ដើម្បីផ្តល់អនុសាសន៍ ។

*ដើម្បីអោយឯកសារវិនិយោគបីឆ្នាំរំកិលរបស់ឃុំសង្កាត់ មានលក្ខណៈគ្រប់ជ្រុងជ្រោយ គ.ផ.ថ ត្រូវ អនុវត្តតាមនិតិវិធីដូចខាងក្រោម :*

**ជំហានទី១១:** ការរៀបចំអនុម័តឯកសារកម្មវិធីវិនិយោគឃុំសង្កាត់

១) ឃុំសង្កាត់ ត្រូវដាក់ជូន ក.វិ.ឃស របស់ខ្លួនទៅអភិបាលខេត្តក្រុង តាមរយៈ អង្គភាពរដ្ឋបាលមូលដ្ឋាន ខេត្តក្រុង ដើម្បីពិនិត្យពីភាពសមស្រប មួយចំនួន ដូចជា:

- ភាពស្របតាមគោលនយោបាយជាតិនិងបទបញ្ញត្តិនានារបស់ក.វិ.ឃស
- ទិដ្ឋភាពបច្ចេកទេសនៃវិធីសាស្ត្ររៀបចំឯកសារក.វិ.ឃស
- លទ្ធភាពនិងភាពអាចអនុវត្តបាននៃគំរោងនានាដែលមាននៅក្នុងកម្មវិធីវិនិយោគ
- ផលប៉ះពាល់គំរោងចំពោះតំបន់រស់នៅរបស់ជនជាតិដើមភាគតិច ។

២) ក្នុងកំឡុងពេលរង់ចាំអនុសាសន៍ពីអភិបាលខេត្តក្រុង មេឃុំចៅសង្កាត់ ត្រូវរៀបចំការបង្ហាញសេចក្តីព្រាងក.វិ.ឃស នៅក្នុងការប្រជុំថ្នាក់ភូមិ ដោយសមាជិកគ.ផ.ថ ព្រមទាំងសមាជិក ក្រុមប្រឹក្សាឃុំសង្កាត់ផ្សេងទៀត ដើម្បីស្រង់ យកមតិសាធារណៈ ហើយកត់ត្រាយោបល់និងការតវ៉ាទាំងឡាយរបស់ប្រជាជន ជាពិសេសចំពោះតំបន់ដែល មានជនជាតិដើមភាគតិចរស់នៅ ។

៣) គ.ផ.ថ ត្រូវប្រជុំពិនិត្យសេចក្តីព្រាងក.វិ.ឃសឡើងវិញ ដោយធ្វើការសំរបសំរួលមតិយោបល់ និងអនុសាសន៍ ទទួលបានពីអភិបាលខេត្តក្រុង ពីអ្នកភូមិ និងអ្នកពាក់ព័ន្ធ ។

៤) មេឃុំចៅសង្កាត់ ត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ ដើម្បីពិភាក្សានិងអនុម័តឯកសារកម្មវិធីវិនិយោគ បីឆ្នាំរំកិលរបស់ឃុំសង្កាត់ខ្លួន ជាផ្លូវការ ។

ដើម្បីដំណើរការប្រជុំពិភាក្សានានា ដូចមានណែនាំខាងលើ គ.ផ.ថ ត្រូវស្នើសុំអង្គភាពរដ្ឋបាលមូលដ្ឋានខេត្តក្រុង អោយផ្តល់អ្នកសំរបសំរួលស្រុកខណ្ឌ ជួយណែនាំនិងសំរបសំរួល ការពិភាក្សានៃកិច្ចប្រជុំរបស់គ.ផ.ថ ប្រកបដោយលទ្ធផលខ្ពស់ ។ ស្មៀនឃុំសង្កាត់ ត្រូវធ្វើកំណត់ហេតុ រាល់ការប្រជុំទាំងអស់ ដើម្បីរក្សាទុកជាឯកសារ ។

ឯកសារណែនាំបច្ចេកទេសសំរាប់អ្នកសំរបសំរួលដំណើរការរៀបចំកម្មវិធីវិនិយោគឃុំសង្កាត់ ត្រូវរៀបចំឡើងដោយឡែកដោយក្រុមការងារនៃអនុគណៈកម្មការផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច ។

មេឃុំចៅសង្កាត់ ត្រូវខិតខំអនុវត្តអោយបានល្អតាមសេចក្តីណែនាំនេះ ដោយធានាថា កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំសង្កាត់ ត្រូវបានរៀបចំឡើងនៅក្នុងស្មារតីតម្លាភាពនិងមានការចូលរួមពីអ្នកពាក់ព័ន្ធ ។ ៥

រាជធានីភ្នំពេញ, ថ្ងៃទី ១៧... ខែ កក្កដា ឆ្នាំ២០០៣

**រដ្ឋមន្ត្រីក្រសួងផែនការ**

**និងជា**

**ប្រធានអនុគណៈកម្មការផែនការនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច**

ឆាយ ថន

**ចំលងជូន:**

- គ.ឃ.ស
- ក្រសួងមហាផ្ទៃ
  "ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្ត ក្រុង
- អង្គភាពរដ្ឋបាលមូលដ្ឋាន
  "ដើម្បីសហការអនុវត្ត"
- មន្ទីរផែនការ "ដើម្បីអនុវត្ត"

៧៥៧